មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក
ខែឧសភា ឆ្នាំ២០១៤
ក្រមព្រហ្មទណ្ឌក្នុងបទបរិហារកេរ្តិ៍ និងសេរីភាពបញ្ចេញមតិនៅកម្ពុជា

ខ្លឹមសារសង្ខេប

កំណត់ត្រាសង្ខេបនេះបង្ហាញពីទិដ្ឋភាពច្បាប់ជាតិ និងអន្តរជាតិដែលចែងពីក្រមព្រហ្មទណ្ឌនៃការបរិហារកេរ្តិ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។ រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បានប្រើបញ្ញត្តបរិហារកេរ្តិ៍នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ("ក្រមព្រហ្មទណ្ឌ") ជាឧបករណ៍ដើម្បីបង្ក្រាបលើសេរីភាពនិយាយស្តីរបស់អ្នកសារព័ត៌មាន អ្នកនយោបាយបក្សប្រឆាំង ព្រមទាំងអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនសិទ្ធិមនុស្ស។[1] ការចាត់ទុកការបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌ បានរារាំងដល់សិទ្ធិសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជា ខណៈដែលសិទ្ធិនេះស្ថិតក្រោមការគំរាមកំហែងនៅឡើយនោះ ដូច្នេះក៏បានរំលោភលើសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋរបស់ខ្លួន ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") និងច្បាប់អន្តរជាតិ។

ផ្នែកទី១នៃកំណត់ត្រាសង្ខេបនេះនឹងបង្ហាញពីច្បាប់បរិហារកេរ្តិ៍នៅកម្ពុជា។ ផ្នែកទី២ នឹងបង្ហាញពីការការពារសិទ្ធិសេរីភាពបញ្ចេញមតិ នៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ក៏ដូចជាការអនុញ្ញាតឲ្យមានការរឹតបន្តឹងទៅលើសិទ្ធិសេរីភាពបញ្ចេញមតិ និងសេចក្តីណែនាំអន្តរជាតិស្តីពីច្បាប់បរិហារកេរ្តិ៍។ ផ្នែកទី៣ នឹងនិយាយលម្អិតពីករណីសិក្សាលើការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ដែលបង្ហាញពីរបៀបនៃការប្រើប្រាស់ការចោទប្រកាន់ក្នុងការរឹតបន្តឹងសេរីភាពបញ្ចេញមតិ។ កំណត់ត្រាសង្ខេបនេះនឹងបញ្ចប់ជាមួយ ការវិភាគលើការរឹតបន្តឹងបទបរិហារកេរ្តិ៍ថ្មីៗ ក្នុងប្រទេសកម្ពុជា ព្រមទាំងបង្ហាញអនុសាសន៍ដាក់ជូនដល់រដ្ឋាភិបាល សម្រាប់ការផ្លាស់ប្តូរដែលរួមមានអនុសាសន៍សំខាន់ៗដូចខាងក្រោម៖

- ដកបទបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌ និងលុបចោលរាល់ច្បាប់ទាំងឡាយណា ដែលមិនស្របតាមរដ្ឋធម្មនុញ្ញ និងបទដ្ឋានច្បាប់អន្តរជាតិ លើសេរីភាពបញ្ចេញមតិ
- ជាវិធានការបណ្តោះអាសន្ន រដ្ឋាភិបាលគួរកំណត់ការអនុវត្តន៍នៃច្បាប់បរិហារកេរ្តិ៍នោះ ចំពោះតែករណីធ្ងន់ធ្ងរប្រឆាំងលើបុគ្គលប៉ុណ្ណោះ និងគួរតែធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌដើម្បីបកស្រាយឲ្យបានច្បាស់នូវពាក្យបច្ចេកទេសដែលមានលក្ខណៈស្រពេចស្រពិល

[1] ម.ស.ម.ក "ការគាបសង្កត់លើការបញ្ចេញមតិ៖ ស្ថានភាពសេរីភាពបញ្ចេញមតិនៅកម្ពុជា" (របាយការណ៍) (ខែកញ្ញា ឆ្នាំ២០១៣) http://bit.ly/1lBgmal

- ចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីកុំឲ្យស្ថាប័នរដ្ឋខ្ជះខ្ជាយធនធានរបស់ជាតិ និងចំណាយពេលវេលាដ៏មានតម្លៃរបស់តុលាការ មកដោះស្រាយបទចោទនានាពីបទបរិហារកេរ្តិ៍។

កំណត់ត្រាសង្ខេបនេះត្រូវបាននិពន្ធឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់និងការពារលិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅទូទាំងប្រទេសកម្ពុជា ដែលក្នុងនោះមានសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ។

សាថតារ

រដ្ឋាភិបាល បានទទួលស្គាល់ម្តងហើយម្តងទៀតពីតម្រូវការក្នុងការធ្វើកំណែទម្រង់ផ្នែកច្បាប់របស់ កម្ពុជាចំពោះករណីបរិហារកេរ្តិ៍ ហើយក៏បានបង្ហាញពីបំណងក្នុងការដកបទបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌផងដែរ។ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៦ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថាការបរិហារកេរ្តិ៍អាចនឹងត្រូវដកចេញពីបទព្រហ្មទណ្ឌ។[2] ទោះជាយ៉ាងណា នៅខែឧសភា ឆ្នាំ២០០៦ នៅពេលរដ្ឋសភាបានធ្វើវិសោធនកម្ម មាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ឆ្នាំ១៩៩២ (“ក្រមព្រហ្មទណ្ឌអ៊ុនតាក់”) ពេលនោះមានតែការដាក់ទោសឲ្យជាប់ពន្ធនាគារពីបទបរិហារកេរ្តិ៍តែប៉ុណ្ណោះ ដែលត្រូវបានលុបចោល។

ការលុបចោលទោសទណ្ឌកម្មជាប់ពន្ធនាគារ មិនអាចចាត់ទុកថាជាការដកបទបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌនោះទេ ដោយសារថាបទល្មើសនេះនៅតែត្រូវបញ្ជូនទៅកាត់ទោសនៅតុលាការព្រហ្មទណ្ឌ។ ប៉ុន្តែ នៅពេលក្រមព្រហ្មទណ្ឌថ្មីចូលជាធរមាននៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ជំនួសឲ្យក្រមព្រហ្មទណ្ឌអ៊ុនតាក់ ក្រមនេះនៅតែចែងពីបទល្មើសបរិហារកេរ្តិ៍ នៅក្នុងមាត្រា ៣០៥។ លើសពីនេះទៀត ការរឹតបន្តឹងមួយចំនួនទៅលើសេរីភាពបញ្ចេញមតិ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌអ៊ុនតាក់ ដូចជាបញ្ញត្តិផ្សាយព័ត៌មានមិនពិត ក្នុងមាត្រា ៦២ នៅតែមានឥទ្ធិពល និងត្រូវបានប្រើក្នុងការរារាំងលើក្រុមអ្នកប្រឆាំង អ្នកការពារសិទ្ធិមនុស្ស និងប្រព័ន្ធផ្សព្វផ្សាយ។[3]

មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ បានកំណត់និយមន័យពាក្យបរិហារកេរ្តិ៍ថា៖ “*ការបរិហារកេរ្តិ៍ ជាការអះអាងបំផ្លើស ឬការទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិសព្ទនៃបុគ្គល ឬនៃស្ថាប័ន*” ។ ក្រមព្រហ្មទណ្ឌពង្រីកនូវវិសាលភាព នៃការបរិហារកេរ្តិ៍ដើម្បីអាចឲ្យមានការដាក់ពាក្យប្តឹងបទល្មើសព្រហ្មទណ្ឌ ករណីដែលមានការបរិហារកេរ្តិ៍លើស្ថាប័ន ឬបុគ្គល ខណៈដែលក្រមព្រហ្មទណ្ឌអ៊ុនតាក់បានបញ្ជាក់ច្បាស់ត្រឹមតែបុគ្គលប៉ុណ្ណោះ។ មាត្រា ៣០៥ នេះផងដែរក៏បានបន្ថយកម្រិតទាបបំផុត ដែលការចោទប្រកាន់ពីបទបរិហារកេរ្តិ៍អាចនឹងកើតមានឡើង។ នៅក្នុងក្រមព្រហ្មទណ្ឌអ៊ុនតាក់ ការនិយាយបំផ្លើសត្រូវតែជាការនិយាយដែលប៉ះពាល់យ៉ាងពិតប្រាកដទៅលើកេរ្តិ៍ឈ្មោះ ឬកិត្តិយស ប៉ុន្តែក្នុង មាត្រា ៣០៥ បានចែងថា ការចោទប្រកាន់អាចធ្វើទៅបាន ប្រសិនបើគ្រាន់តែមានបំណងធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬកេរ្តិ៍ឈ្មោះ។

---

[2] អេលេន ណាកាហ្ស៊ីម៉ា “កម្ពុជាដើរឆ្ពោះទៅរកភាពបើកចំហ” *ឌឺ វ៉ស៊ីងតោន ផូស* (ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦) http://wapo.st/1oV1YxZ

[3] ឧទាហរណ៍ ការដាក់ពន្ធនាគាររបស់បុគ្គលិក លីកាដូ លាង សុខជឿន ដែលផ្តន្ទាទោសពីបទផ្តល់ព័ត៌មានមិនពិត តាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌអ៊ុនតាក់ ឆ្នាំ២០១០។ សូមអានសេចក្តីថ្លែងការណ៍ អង្គការលីកាដូ ដើម្បីព័ត៌មានបន្ថែម http://bit.ly/1gJoB4T

ការផាកពិន័យពីបទបរិហារកេរ្តិ៍គឺចាប់ពី មួយសែនរៀល រហូតដល់ ដប់លានរៀល គឺប្រហែលពី ២៥ ដុល្លារអាមេរិក ដល់ ២៥០០ ដុល្លារអាមេរិក។[4] នេះមិនមែនជាចំនួនមួយតិចនោះទេ ខណៈដែលប្រាក់ខែគោលសម្រាប់វិស័យកាត់ដេរក្នុងប្រទេសនេះទើបតែកើនដល់ ១០០ ដុល្លារអាមេរិក ប៉ុណ្ណោះក្នុងមួយខែ។[5] បន្ថែមពីលើនេះ ថ្វីបើមានការដកទោសទណ្ឌជាប់ពន្ធនាគារ ជាទោសដោយផ្នែលនៃបទល្មើសបរិហារកេរ្តិ៍ក៏ដោយ ក៏ប្រជាពលរដ្ឋកម្ពុជាអាចនឹងត្រូវជាប់ពន្ធនាគារ តាមមាត្រា ៥២៥ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដោយសារតែការមិនបង់ប្រាក់ផាកពិន័យទៀតផង។[6] យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ការដាក់ពន្ធនាគារគឺចាប់ពី ១០ ថ្ងៃ ទៅ ២ឆ្នាំ។ ពលរដ្ឋកម្ពុជាអាចត្រូវប្រឈមការដាក់ពន្ធនាគារយៈពេល ៦ខែ សម្រាប់ការមិនបង់ប្រាក់ពិន័យដែលចន្លោះពី ប្រាំលានមួយរៀល ទៅ ដប់លានរៀល ជាការផាកពិន័យអតិបរមាក្នុងបទបរិហារកេរ្តិ៍។[7]

បន្ថែមពីលើមាត្រា ៣០៥ នេះទៀត មានមាត្រាផ្សេងទៀតនៃក្រមព្រហ្មទណ្ឌ ដែលធ្វើឲ្យប៉ះពាល់បន្ថែមទៀតទៅលើសេរីភាពបញ្ចេញមតិ ដែលក្នុងនោះរួមបញ្ចូលទាំង បទជេរប្រមាថជាសាធារណៈ (មាត្រា ៣០៧) បទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ (មាត្រា ៥២៣) និងបទប្រមាថលើមន្ត្រីសាធារណៈ (មាត្រា ៥០២)។ ច្បាប់ទាំងនេះ តែងតែមានលក្ខណៈមិនច្បាស់លាស់ ហើយទុកឲ្យមានការបកស្រាយមកពីប្រព័ន្ធតុលាការ។ ឆន្ទានុសិទ្ធិរបស់តុលាការដែលមានលក្ខណៈទូលាយ ចំពោះការបកស្រាយច្បាប់ ជារឿយៗធ្វើឲ្យមានការអនុវត្ត និងការបកស្រាយផ្សេងគ្នាទៅលើច្បាប់នេះពីសំណាក់តុលាការ ដូចដែលកើតមានក្នុងប្រព័ន្ធច្បាប់នៃប្រទេសជាតិណាផ្សេង។

បន្ថែមពីលើនេះទៅទៀត ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥ ("ច្បាប់សារព័ត៌មាន") របស់ប្រទេសកម្ពុជា ចែងពីការរឹតបន្តឹងដោយមិនច្បាស់លាស់ ចំពោះការបោះពុម្ពផ្សាយក្នុងនោះរួមបញ្ចូលទាំងឃ្លាថា "*អ្វីដែលធ្វើឲ្យប៉ះពាល់ដល់ទំនៀមទម្លាប់ល្អរបស់សង្គម*" ។[8] ដូចគ្នានឹង មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌដែរ ដែលអនុញ្ញាតឲ្យតុលាការសម្រេចថាតើអ្វី "*ដែលមានបំណងធ្វើឲ្យប៉ះពាល់កិត្តិយស ឬកេរ្តិ៍ឈ្មោះ*" ឃ្លាឃ្លោងក្នុងច្បាប់សារព័ត៌មាន អនុញ្ញាតឲ្យតុលាការសម្រេចថាអ្វី "ដែលអាចនឹង" ប៉ះពាល់ដល់ សណ្តាប់ធ្នាប់សាធារណៈ ស្ថិរភាពនយោបាយ ឬទំនៀមទម្លាប់ល្អរបស់សង្គម។[9] អំណាចក្នុងការបកស្រាយថាតើបទល្មើសណាមួយត្រូវបានប្រព្រឹត្តពិតមែននោះ ត្រូវបានផ្តល់ឲ្យទៅប្រព័ន្ធតុលាការច្រើនហួសហេតុពេក។ ការធ្វើបែបនេះ នឹងចោទជាបញ្ហានៅក្នុងសង្គមដែលគួរតែមានប្រព័ន្ធយុត្តិធម៌ឯករាជ្យពេញលេញ ជាអ្វីដែលកម្ពុជាកំពុងខ្វះខាត។[10]

បទបរិហារកេរ្តិ៍ក្នុងច្បាប់អន្តរជាតិ

ការទុកបទបរិហារកេរ្តិ៍ជាបទល្មើសព្រហ្មទណ្ឌ ក្នុងប្រព័ន្ធច្បាប់ណាក៏ដោយ ត្រូវបានរិះគន់ដោយអង្គការអន្តរជាតិ ទាក់ទិននឹងការរំលោភសិទ្ធិសេរីភាពបញ្ចេញមតិ ដែលក្នុងនោះរួមមានទាំងគណៈកម្មាធិការសិទ្ធិ

---

[4] ក្រមព្រហ្មទណ្ឌ មាត្រា ៣០៥ http://bit.ly/1flnnbx

[5] អូន ភាព និង ខូលីន មេយ៍ "ក្នុងចំណោមការធ្វើបាតុកម្ម រដ្ឋមន្ត្រីដំឡើងប្រាក់ឈ្នួលអប្បបរមាដល់ ១០០ ដុល្លារអាមេរិក" *ឌឺ ខែមបូឌា ដេលី* (ថ្ងៃទី១ ខែមករា ឆ្នាំ២០១៤) http://bit.ly/1dtByPj

[6] តាមមាត្រា ៥២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការផ្តន្ទាទោសចំពោះការមិនបង់ប្រាក់ពិន័យគឺការជាប់ពន្ធនាគារ។

[7] ម.ស.ម.ក "កំណត់ត្រាសង្ខេប៖ ការពិនិត្យមើលឡើងវិញនូវច្បាប់ផ្សេងៗដែលទាក់ទងនឹងសេរីភាពបញ្ចេញមតិ" (កំណត់ត្រាសង្ខេប) (ខែតុលា ឆ្នាំ២០១២) http://bit.ly/1kxh8sC

[8] មាត្រា ១៣ នៃច្បាប់ស្តីពីរបបសារព័ត៌មាន

[9] ដូចខាងលើ មាត្រា ១២ និង ១៣

[10] ម.ស.ម.ក៖ "កំណែទម្រង់ប្រព័ន្ធតុលាការ" (កំណត់ត្រាសង្ខេប) (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1kmEsq5

មនុស្សអង្គការសហប្រជាជាតិ ជាអង្គការមួយដែលធ្វើការត្រួតពិនិត្យលើការអនុវត្ត កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន)។ សេរីភាពបញ្ចេញមតិត្រូវបានផ្តល់ឲ្យ ទាំងនៅក្នុងច្បាប់អន្តរជាតិ និងក្នុងច្បាប់ជាតិនៃកម្ពុជា ហើយបញ្ញត្តសម្រាប់សេរីភាពត្រូវបានគេពិចារណា ក្នុងពេលពិនិត្យឡើងវិញពីភាពស្របច្បាប់ និងធម្មនុញ្ញភាពនៃច្បាប់បរិហារកេរ្តិ៍នេះក្នុងមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ។

រដ្ឋធម្មនុញ្ញ ដោយឯករាជ្យចែងពីសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ទទួលបានសេរីភាពបញ្ចេញមតិ និងសេរីភាពខាងសារព័ត៌មាន ពោលគឺនៅក្នុងមាត្រា ៣១ ៣៥ និង៤១។[11] បន្ថែមពីលើនេះទៀត រដ្ឋធម្មនុញ្ញក៏បាន *"ការពារសិទ្ធិប្រជាពលរដ្ឋខ្មែរ ក្នុងការចូលរួមយ៉ាងសកម្មក្នុងឆាកនយោបាយ"*[12]។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបង្ហាញថា ប្រទេសកម្ពុជានឹងទទួលស្គាល់ និងគោរពតាមសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយបញ្ចូល កតិកាសញ្ញា និងអនុសញ្ញាទាំងនេះ និងផ្សេងទៀតដែលទាក់ទងនឹងសិទ្ធិមនុស្សទៅក្នុងច្បាប់ជាតិ។[13] ក្រោមច្បាប់អន្តរជាតិ មាត្រា ១៩ នៃសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានលើកកម្ពស់សិទ្ធិសេរីភាពបញ្ចេញមតិ។ សន្ធិសញ្ញាអន្តរជាតិទាំងនេះ និងគណៈកម្មាធិការសិទ្ធិមនុស្ស បានកត់សម្គាល់ឃើញពីសារៈសំខាន់របស់សេរីភាពបញ្ចេញគំនិត និងសេរីភាពបញ្ចេញមតិ ដែលជាមូលដ្ឋានស្នូលសម្រាប់ការអភិវឌ្ឍសង្គមប្រជាធិបតេយ្យ។[14]

ទោះជាយ៉ាងណាក៏ដោយ សិទ្ធិសេរីភាពបញ្ចេញមតិ មិនដាច់ខាតនោះទេ។ ការរឹតបន្តឹងដែលជាក់លាក់ជាច្រើនទៅលើសិទ្ធិ ត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ និងកាលៈទេសៈជាក់លាក់ណាមួយ។ ប៉ុន្តែ ការរឹតបន្តឹង ដែលរួមបញ្ចូលទាំងច្បាប់បរិហារកេរ្តិ៍ផងនោះ អាចទទួលយកបានតែក្នុងស្ថានភាពពិសេសណាមួយប៉ុណ្ណោះ។ ក្នុងមាត្រា ១៩ នៃ ក.អ.ស.ព.ន បានបង្ហាញថាសេរីភាពបញ្ចេញមតិក៏អាចនឹងត្រូវរឹតបន្តឹង ដើម្បីការពារ *"សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬសុខភាព ឬសីលធម៌សាធារណៈ"* ។ ប្រសិនបើរដ្ឋកំហិតសេរីភាពនេះតាមរយៈច្បាប់បរិហារកេរ្តិ៍ នោះអាស្រ័យលើរដ្ឋក្នុងការបង្ហាញថា ការកំហិតទាំងនោះ (១) ត្រូវផ្តល់ដោយច្បាប់ (២) មានភាពចាំបាច់ (៣) មានតួនាទីសមាមាត្រ និង (៤) មិនបម្រើឲ្យការរារាំងសេរីភាពបញ្ចេញមតិ។

យោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស រដ្ឋភាគីទាំងអស់នៃ ក.អ.ស.ព.ន គួរពិចារណាដកការបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌ។[15] ប៉ុន្តែយ៉ាងណាក្តី ស្របពេលដែលការបរិហារកេរ្តិ៍ មិនគួរចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ហើយបើមានច្បាប់ចែងពីការផ្តន្ទាទោស និងផាកពិន័យចំពោះបទល្មើសព្រហ្មទណ្ឌ ការដាក់ទោស

[11] មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ

[12] ដូចខាងលើ មាត្រា ៣៥

[13] យោងតាមការអះអាងតាមរយៈសេចក្តីសម្រេច របស់ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) <http://bit.ly/1rmdbcj>.

[14] គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប សេចក្តីអត្ថាធិប្បាយទូទៅលេខ ៣៤ (ឆ្នាំ២០១១) កថាខណ្ឌទី ២

[15] គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប ធ្វើសេចក្តីសន្និដ្ឋានការអង្កេតលើប្រទេសអ៊ីតាលី កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ/គ/សេចក្តីសន្និដ្ឋានការអង្កេត/៥។

នោះគួរតែអនុវត្តតាមគោលការណ៍ណែនាំនៃមាត្រា ១៩ នៃ ក.អ.ស.ព.ន[16] ដែលថា រដ្ឋាភិបាលត្រូវធានាថា ច្បាប់នៅតែចាំបាច់ និងសមហេតុផលក្នុងន័យការពារកិត្តិសព្ទរបស់ប្រជាពលរដ្ឋ ខណៈដែលតុលាការត្រូវតែបកស្រាយ និងអនុវត្តច្បាប់នោះដោយយុត្តិធម៌ និងមិនលម្អៀង។ រដ្ឋាភិបាលណាដែលប៉ុនប៉ងកំណត់ការបរិហារកេរ្តិ៍ជាបទល្មើសព្រហ្មទណ្ឌ គួរតែមានភស្តុតាងបង្ហាញថា មិនមានវិធីផ្សេងទៀតដែលស័ក្តិសមក្នុងការការពារកិត្តិសព្ទក្រៅពីការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនេះទេ ហើយការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនេះ គឺស្របច្បាប់ និងមិនបានរឹតត្បិតលើសេរីភាពបញ្ចេញមតិនោះទេ។

នៅពេលអនុវត្តច្បាប់នេះ គណៈកម្មាធិការសិទ្ធិមនុស្សថ្លែងបញ្ជាក់ថា ច្បាប់នេះមិនគួរអនុវត្តចំពោះគំនិតយោបល់ ឬការវាយតម្លៃសុទ្ធសាធនោះទេ[17] និងគួរតែអនុញ្ញាតឲ្យការការពារភាពត្រឹមត្រូវ ដើរតួជាអំណះអំណាងស្របច្បាប់នៅពេលប្រឈមនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍។ [18] គោលការណ៍ណែនាំដទៃទៀត រួមមាន (១) មិនដាក់ទោសចំពោះការចេញផ្សាយដោយចៃដន្យនៃសេចក្តីថ្លែងការណ៍មិនពិត[19](២) អនុញ្ញាតឲ្យប្រយោជន៍សាធារណៈជាការការពារស្របច្បាប់នៃការបរិហារកេរ្តិ៍ដែលនឹងអាចកើតមាន[20] (៣) និង សរុបមកបញ្ចៀសការដាក់ទោសទណ្ឌធ្ងន់ធ្ងរពេក។[21]

ការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ គួរត្រូវអនុវត្តតែក្នុងករណីធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ រួមជាមួយនឹងការរឹតត្បិត។ ការដាក់ពន្ធនាគារ ក៏គួរតែជៀសវាងផងដែរ ហើយការជំនុំជម្រះក្តីគួរតែធ្វើឡើងជាប្រញាប់។ ការរឹតត្បិតក៏ទាមទារឲ្យមានការលើកលែងទោសជនជាប់ចោទពីបទបរិហារកេរ្តិ៍ផងដែរ ប្រសិនបើសម្តីបរិហារនោះជាការពិត ធ្វើឡើងដោយគ្មានគំនិតព្យាបាទ ឬពាក់ព័ន្ធនឹងការរិះគន់ ដែលធ្វើឡើងក្នុងន័យផលប្រយោជន៍សាធារណៈ។ គណៈកម្មាធិការសិទ្ធិមនុស្ស ថ្លែងបញ្ជាក់ផងដែរថា ប្រព័ន្ធផ្សព្វផ្សាយ អ្នកបោះពុម្ពផ្សាយ ឬអ្នកសារព័ត៌មានមិនអាចត្រូវបានដាក់ទោសទណ្ឌ ដោយគ្រាន់តែរិះគន់លើរដ្ឋាភិបាល ឬប្រព័ន្ធនយោបាយនោះទេ។[22]

គណៈកម្មាធិការសិទ្ធិមនុស្ស ក៏បានលើកឡើងពីភាពផ្សេងគ្នាក្នុងច្បាប់បរិហារកេរ្តិ៍ ពេលអនុវត្តចំពោះអង្គភាពរដ្ឋ និងអង្គភាពឯកជន។ បុគ្គលសាធារណៈទាំងអស់ រួមទាំង ថ្នាក់ដឹកនាំខ្ពស់បំផុត គឺជាបុគ្គលធម្មានុរូប

[16] គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប សេចក្តីសន្និដ្ឋានការអង្កេតលើប្រទេស យូហ្គោស្លាវី ក.ន.ព.ស /គ/ MKD/សេចក្តីសន្និដ្ឋានការអង្កេត/២។

[17] គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប វិចារណៈកថាទូទៅលេខ ៣៤ (ឆ្នាំ២០១១)។

[18] គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប ធ្វើសេចក្តីសន្និដ្ឋានការអង្កេតលើ ចក្រក្រុកពអង់គ្លេស និងភាគខាងជើងនៃប្រទេសអៀរឡង់ ក.ន.ព.ស /គ/ GBR/សេចក្តីសន្និដ្ឋានការអង្កេត/៦។

[19] មានប្រភពដូចខាងលើ។

[20] មានប្រភពដូចខាងលើ។

[21] មានប្រភពដូចខាងលើ។

[22] គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប សេចក្តីសន្និដ្ឋានការអង្កេតលើប្រទេសប៉េរ៉ូ កតិកាសញ្ញាសន្ធិមនុស្ស/សេចក្តីសន្និដ្ឋានការអង្កេត/៧០/ PER។

ចំពោះការរិះគន់ រួមទាំងគណបក្សប្រឆាំងផងដែរ។[23] ការកំណត់លើការរិះគន់ដែលអាចទទួលបាន សម្រាប់អ្នកនយោបាយ មានលក្ខណៈទូលំទូលាយជាងបុគ្គលឯកជន[24] ហើយស្ថាប័នរដ្ឋ មិនអនុញ្ញាតឲ្យធ្វើការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ប្រឆាំងលើបុគ្គលឯកជនណាម្នាក់ ឬអង្គការនោះទេ។ គេមិនអាចមើលតួអង្គសាធារណៈ ជាអ្នកមាន "កិត្តិសព្ទ" នោះឡើយ ព្រោះថា ពួកគេខ្វះផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងផ្នែកស្មារតី ក្នុងការ ការពារដល់ការខូតខាតកិត្តិនាមរបស់ខ្លួន។ នេះក៏អាចចាត់ទុកថាជាការមិនសមហេតុផលក្នុងការចំណាយ ថវិការដ្ឋដើម្បីចំណាយក្នុងការដាក់ពាក្យប្តឹងបទបរិហារកេរ្តិ៍ផងដែរ។ ការលើកឡើងទាំងនេះ ធ្វើឡើងដើម្បីការពារសិទ្ធិសេរីភាពបញ្ចេញមតិ។ មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ រំលោភលើលក្ខខណ្ឌទាំងនេះ ជាពិសេស ដោយសារការបរិហារកេរ្តិ៍ អាចធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិសព្ទរបស់ "ស្ថាប័ន" ណាមួយនោះ។

<u>វិធានការបណ្តោះអាសន្ន</u>

អង្គការមាត្រា ១៩ ជាអង្គការមិនមែនរដ្ឋាភិបាលឈានមុខអន្តរជាតិ ធ្វើការដើម្បីលើកកម្ពស់សិទ្ធិសេរីភាពបញ្ចេញមតិ សេរីភាពទទួលបានព័ត៌មាន និងសេរីភាពប្រព័ន្ធផ្សព្វផ្សាយ បានចេញផ្សាយវិធានការបណ្តោះអាសន្នដើម្បីលើកឡើងពីបទល្មើសបរិហារកេរ្តិ៍ ដែលនៅតែមិនទាន់បានដកចេញពីបទល្មើសព្រហ្មទណ្ឌទាំងស្រុងនោះទេ។[25] បទដ្ឋានអប្បបរមាទាំងនេះ អនុលោមស្របតាមច្បាប់អន្តរជាតិ រួមមាន៖

១. គ្មានជនណាម្នាក់ ត្រូវបានផ្តន្ទាទោសពីករណីបរិហារកេរ្តិ៍នោះទេ លើកលែងតែភាគីដែលអះអាងថាខ្លួនត្រូវបានបរិហារកេរ្តិ៍ ដោយរួចផុតពីវិមតិសង្ស័យ អាចបង្ហាញនូវតួមាននៃធាតុផ្សំទាំងអស់នៃបទល្មើស ដូចមានចែងខាងក្រោម

២. បទល្មើសបរិហារកេរ្តិ៍ នឹងមិនអាចកើតឡើងបានទេ លើកលែងតែ មានការបង្ហាញថា សម្តីរិះគន់នោះមិនត្រឹមត្រូវ គឺថានិយាយដោយដឹងច្បាស់ថាពុំមែនជាការពិត ឬដោយភាពធ្វេសប្រហែស មិនច្បាស់លាស់ថាតើសម្តីនោះពិតប្រាកដ ឬមិនពិតប្រាកដ ហើយធ្វើឡើងដោយចេតនាពិតប្រាកដក្នុងការបង្កឲ្យមានផលប៉ះពាល់ដល់ភាគីដែលបានអះអាងថាខ្លួនត្រូវបានបរិហារកេរ្តិ៍។

៣. អាជ្ញាធររដ្ឋនានា រួមមាន នគរបាល និងព្រះរាជអាជ្ញា មិនគួរចូលរួមក្នុងការផ្តួចផ្តើម ឬធ្វើការចោទប្រកាន់ពីករណីបរិហារកេរ្តិ៍ឡើយ ដោយមិនគិតដល់ឋានៈរបស់ភាគីដែលបានអះអាងថាខ្លួនត្រូវបានគេបរិហារកេរ្តិ៍ បើទោះជាបុគ្គលនោះ ជាមន្ត្រីជាន់ខ្ពស់ក៏ដោយ។

៤. ទោសជាប់ពន្ធនាគារ ការព្យួរទោសជាប់ពន្ធនាគារ ការព្យួរសិទ្ធិបញ្ចេញមតិតាមរយៈទម្រង់នៃប្រពន្ធផ្សព្វផ្សាយជាក់លាក់ណាមួយ ឬការព្យួរការប្រកបវិជ្ជាជីវៈសារព័ត៌មាន ឬវិជ្ជាជីវៈដទៃណាមួយ ការពិន័យហួសហេតុ ការដាក់ទោសព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរ មិនគួរប្រើជាទណ្ឌកម្មសម្រាប់ការរំលោភច្បាប់ស្តីពីការបរិហារកេរ្តិ៍ មិនថា សេចក្តីថ្លែងបរិហារកេរ្តិ៍នោះ ធ្ងន់ធ្ងរ ឬធ្វើឡើងដោយឥតលាក់លៀមក៏ដោយ។

---

[23] គណៈកម្មាធិការសិទ្ធិមនុស្ស វិចារណៈកថាទូទៅ លេខ ៣៤ (ឆ្នាំ២០១១)។

[24] លីនហ្គេន និង អ៊ោសស្ត្រា (ឆ្នាំ១៩៨៦) ៨ EHRR ៤០៧។

[25] អង្គការមាត្រា ១៩ "បទបរិហារកេរ្តិ៍" អាចរកបានតាមរយៈ http://bit.ly/1jKtYki។

នៅកម្ពុជា ការអនុវត្តច្បាប់គឺធ្វើឡើងដើម្បីរឹតត្បិតការបញ្ចេញមតិ ដែលរំលោភលើគណៈកម្មាធិការសិទ្ធិមនុស្ស ដូចបានបង្ហាញក្នុងករណីសិក្សានៅផ្នែកបន្ទាប់នេះ។ បទល្មើសព្រហ្មទណ្ឌ ជុំវិញការបរិហារកេរ្តិ៍នៅកម្ពុជា ក្នុងមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ គឺជាការរឹតត្បិតដោយពុំចាំបាច់ និងពុំសមហេតុផលលើសិទ្ធិសេរីភាពបញ្ចេញមតិ ហើយជាក់ស្តែង គឺអនុវត្តដើម្បីបង្ក្រាបលើការប្រឆាំងដោយស្របច្បាប់ ការរិះគន់ និងសេរីភាពរបស់បុគ្គលឯកជន និងប្រព័ន្ធផ្សព្វផ្សាយ។ ការធ្វើបែបនេះគឺ រំលោភលើសិទ្ធិសេរីភាពបញ្ចេញមតិរបស់ពលរដ្ឋ និងជាឧបសគ្គចម្បងចំពោះការវិវឌ្ឍន៍ទៅនៃសង្គមប្រជាធិបតេយ្យ។

ករណីសិក្សា

ករណីខាងក្រោម ជាករណីដែលប្រជាពលរដ្ឋកម្ពុជា អនុវត្តសេរីភាពបញ្ចេញមតិរបស់ខ្លួនស្របតាមច្បាប់ តែពួកគាត់ប្រឈមនឹងការធ្វើទុក្ខបុកម្នេញ និងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌនានា បង្ហាញឲ្យឃើញច្បាប់ពីវិធីដែលការចាត់ការបរិហារកេរ្តិ៍ជាបទល្មើសព្រហ្មទណ្ឌ ទាំងនៅក្រោមក្រមព្រហ្មទណ្ឌ អ៊ុនតាក់ និងក្រមព្រហ្មទណ្ឌបច្ចុប្បន្ននេះ បានបន្តរារាំងសេរីភាពបញ្ចេញមតិនៅកម្ពុជា។ បន្ថែមពីលើនោះ ករណីខ្លះៗក្នុងចំណោមករណីទាំងនេះ បង្ហាញពីនិន្នាការយ៉ាងច្បាស់របស់រដ្ឋាភិបាល ក្នុងការប្រើប្រាស់ការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ដើម្បីគាបសង្កត់អ្នកដែលហ៊ាននិយាយរិះគន់រដ្ឋាភិបាល និងគោលនយោបាយរបស់រដ្ឋាភិបាល។

<u>លោក ដាំ សិទ្ធិ</u>

លោក ដាំ សិទ្ធិ ជានិពន្ធនាយកកាសែតគាំទ្រគណបក្សប្រឆាំងជាខេមរភាសាឈ្មោះ *មនសិការខ្មែរ* ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត និងបទបរិហារកេរ្តិ៍ ក្នុងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ អ៊ុនតាក់ កាលពីខែមិថុនា ឆ្នាំ២០០៨ ដោយសារបានចេញផ្សាយអត្ថបទមួយ ដែលដកស្រង់សម្តីរបស់ លោក សម រង្ស៊ី ចោទប្រកាន់ លោក ហោ ណាំហុង រដ្ឋមន្ត្រីការបរទេស ថាពាក់ព័ន្ធក្នុងរបបខ្មែរក្រហម។ លោក ដាំ សិទ្ធិ ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នជាងមួយសប្តាហ៍នៅក្នុងពន្ធនាគារ មុនពេលដែលលោកត្រូវបានដោះលែងវិញ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៨ បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើឲ្យដោះលែងរូបលោកជាបណ្តោះអាសន្ន។[26] ការចោទប្រកាន់នោះ ក្រោយមកត្រូវទម្លាក់ចោលវិញ។ មួយខែក្រោយមក លោក ឃឹម សំបូរ អ្នកសារព័ត៌មាន កាសែត *មនសិការខ្មែរ* ដែលបានតែងតែរាយការណ៍ពីករណីអំពើពុករលួយរបស់រដ្ឋាភិបាល ត្រូវបានឃាតករបាញ់សម្លាប់ ជាមួយនឹងកូនប្រុសអាយុ ២១ ឆ្នាំ របស់លោក។[27]

នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ លោក ដាំ សិទ្ធិ ត្រូវបានតុលាការកោះហៅឲ្យចូលឆ្លើយបំភ្លឺ ក្រោមការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់។ មួយសប្តាហ៍ក្រោយមក បទចោទប្រកាន់នានាលើរូបលោក ត្រូវបានទម្លាក់ បន្ទាប់ពីលោកសរសេរលិខិតមួយច្បាប់សុំទោសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយស្នើថានឹងបិទកាសែតនោះ ជាថ្នូរនឹងការបញ្ឈប់ការចោទប្រកាន់ពីបទព្រហ្មទណ្ឌប្រឆាំងលើរូប

---

[26] ជាង សុខា "និពន្ធនាយកកាសែតរបស់គណបក្សប្រឆាំង ត្រូវបានដោះលែងពីពន្ធនាគារ ដោយរងចាំការជំនុំជម្រះក្តីពីបទបរិហារកេរ្តិ៍" កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨) អាចរកបានតាមរយៈ http://bit.ly/1jf4c86។

[27] ករណីសិក្សាជុំវិញការសម្លាប់អ្នកសារព័ត៌មានទាំងនេះនៅកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៤ អាចរកបានតាម៖ http://bit.ly/1iCILvW។

លោក។[28]នៅដើមឆ្នាំដដែលនោះ និពន្ធនាយករបស់សារព័ត៌មានប្រឆាំងចំនួនពីរផ្សេងទៀត កាសែត *សេរីភាពថ្មី* និងកាសែត *ខ្មែរម្ចាស់ស្រុក* ក៏ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងបទផ្សព្វផ្សាយព័ត៌មានមិនពិតផងដែរ។ ម្នាក់ក្នុងចំណោមនោះ គឺ លោក ហង្ស ចក្រា និពន្ធនាយក កាសែត *ខ្មែរម្ចាស់ស្រុក* ត្រូវបានតុលាការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ១ ឆ្នាំ។[29]

ករណីទាំងនេះ បង្ហាញយ៉ាងច្បាស់លាស់នូវការប្រើប្រាស់បទល្មើសបរិហារកេរ្តិ៍ជាបទល្មើសព្រហ្មទណ្ឌពីសំណាក់រដ្ឋាភិបាល ដើម្បីបំបិទសំឡេងអ្នកសារព័ត៌មាន និងនិពន្ធនាយក ដែលរិះគន់រដ្ឋាភិបាល និងគណបក្សកាន់អំណាច។ ដោយសារការចោទប្រកាន់ពីបទព្រហ្មទណ្ឌនានា រួមមាន បទផ្សព្វផ្សាយព័ត៌មានមិនពិត និងបទបរិហារកេរ្តិ៍ ជាដើម ប្រឆាំងថ្នាក់ដឹកនាំគណបក្សប្រឆាំង រួមមាន លោក សម រង្ស៊ី[30] លោកស្រី មូរ សុខហួរ[31] និង លោក ហូ វ៉ាន់[32] ក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ បទចោទលើលោក ដាំ សិទ្ធិ ព្រមទាំងលើនិពន្ធនាយកដទៃទៀត បានបង្ហាញយ៉ាងច្បាស់ថានេះជាការវាយប្រហារដោយផ្ទាល់ទៅលើគណបក្សប្រឆាំង និងអ្នកគាំទ្រគណបក្សប្រឆាំង។

---

[28] ម.ស.ម.ក "ការសុំទោសរបស់លោក ដាំ សិទ្ធិ គឺជាយុទ្ធនាការរបស់រដ្ឋាភិបាល ដើម្បីបំបាត់សំឡេងប្រឆាំង" (សេចក្តីថ្លែងការណ៍) (ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩) អាចរកបានតាម៖http://bit.ly/1eqR0yy។

[29] មានប្រភពដូចខាងលើ។

[30] លោក សម រង្ស៊ី បានប្រឈមនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងការផ្សព្វផ្សាយព័ត៌មានមិនពិត ជាច្រើនលើកច្រើនសារ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៩ អភ័យឯកសិទ្ធិសភារបស់លោកត្រូវបានដកហូត បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្តឹងរូបលោកពីបទបរិហារកេរ្តិ៍ ផ្អែកលើមតិយោបល់របស់លោក ដោយលោកបានចោទលោក ហ៊ុន សែន ពីបទពុករលួយ សូមមើល សេចក្តីថ្លែងការណ៍របស់ អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) "កម្ពុជា៖ ការជំនុំជម្រះក្តីថ្នាក់ដឹកនាំគណបក្សប្រឆាំងលោក សម រង្ស៊ី (សេចក្តីថ្លែងការណ៍) (ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០) អាចរកបានតាម៖http://bit.ly/1eYR1tP ម.ស.ម.ក "ការវិភាគមូលដ្ឋានផ្លូវច្បាប់ចំពោះការចោទប្រកាន់ និងភាពយុត្តិធម៌នៃដំណើរការរបស់តុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌប្រឆាំងលើរូបលោក សម រង្ស៊ី" (ខែកុម្ភៈ ឆ្នាំ២០១១) អាចរកបានតាមរយៈ) http://bit.ly/1i4KsW0។

[31] នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ លោកស្រី មូរ សុខហួរ បានប្តឹងលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយចោទនាយករដ្ឋមន្ត្រីពីបទបរិហារកេរ្តិ៍ ក្រោមមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ អ៊ុនតាក់ ជាការឆ្លើយតបទៅនឹងសុន្ទរកថាមួយដែលលោកនាយករដ្ឋមន្ត្រីបានហៅសំដៅលើស្ត្រីតំណាងរាស្ត្ររបស់គណបក្សប្រឆាំងមិនបញ្ចេញឈ្មោះមួយរូប ថាជា *"ជើងខ្លាំង"* ដែលជាពាក្យសម្តីបង្អាប់បង្អោនចំពោះស្ត្រី ជាពិសេស នៅពេលដែលពាក្យសម្តីនេះត្រូវបានប្រើសំដៅលើស្ត្រី ដោយថ្លែងថា ជាស្ត្រីពេស្យា។ បន្ទាប់ពីលោក នាយករដ្ឋមន្ត្រី បដិសេធមិនដកពាក្យសម្តី លោកស្រី មូរ សុខហួរ បានដាក់ពាក្យបណ្តឹងទាមទារសំណងជម្ងឺចិត្តទឹកប្រាក់ចំនួន ៥០០រ។ លោកនាយករដ្ឋមន្ត្រីបានប្តឹងបកវិញ ដោយអះអាងថា លោកស្រី មូរ សុខហួរ បានបរិហារកេរ្តិ៍បលោក ដោយថ្លែងថា ពាក្យសម្តីបង្អាប់បង្អោនរបស់លោកនាយករដ្ឋមន្ត្រី បានប៉ះពាល់ដល់ស្ត្រីខ្មែរគ្រប់រូប។ អានបន្ថែមទៀត៖ ម.ស.ម.ក សំណុំរឿងនៃព្រះរាជាណាចក្រកម្ពុជា និងលោកស្រី មូរ សុខហួរ (ការវិភាគផ្លូវច្បាប់) (ខែឧសភា) (ឆ្នាំ២០១០) អាចរកបានតាម៖http://bit.ly/1tvBVzN ម.ស.ម.ក "ទិដ្ឋភាពទូទៅនៃអភ័យឯកសិទ្ធិសភា ក្រោមច្បាប់កម្ពុជា" (កំណត់ត្រាសង្ខេប) (ខែធ្នូ ឆ្នាំ២០១២) http://bit.ly/1gOqQAZ។

[32] នៅក្នុងខែកញ្ញា ឆ្នាំ ២០០៩ ឯកឧត្តម ហូ វ៉ាន់ តំណាងរាស្ត្រគណបក្សប្រឆាំង ត្រូវបានតុលាការកាត់ទោសពីបទបរិហារកេរ្តិ៍លើមន្ត្រីកងរាជអាវុធហត្ថចំនួន២២នាក់ ដែលមានទំនាក់ទំនងស្និទ្ធជាមួយគណៈប្រជាជនតាមរយៈការដកស្រង់សម្តី បានរាយការណ៍ដោយកាសែត *ឌឺ ខេមបូឌា ដេលី*។ លោក ខេវិន ដូលយ៍ ប្រធាននិពន្ធនាយកកាសែតនោះ និង អ្នកសរសេរអត្ថបទ លោក នៅ វណ្ណារិន ក៏ត្រូវបានចោទប្រកាន់ពីបង្ខូចកេរ្តិ៍ក្រោមច្បាប់ស្តីពីរបបសារព័ត៌មានដែរ។ លោក ហូ វ៉ាន់ បានលើកឡើងថា លោកត្រូវបានគេដកស្រង់សម្តីពុំត្រឹមត្រូវនៅក្នុងអត្ថបទនោះ លោកត្រូវបានលើកលែងការចោទប្រកាន់វិញ ខណៈដែល លោក ខេវិន ដូលយ៍ និង នៅ វណ្ណារិន ត្រូវបានតុលាការបង្គាប់ឲ្យបង់ប្រាក់ចំនួនបួនរៀលក្នុងម្នាក់ៗ។ លោកមាស សុខដា និងចេម អូចូល "តុលាការលើកលែងការចោទប្រកាន់លោក ហូ វ៉ាន់ កាសែត *ភ្នំពេញប៉ុស្តិ៍* (រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩) អាចរកបានតាមរយៈ:http://bit.ly/1kVwG8K។

<u>លោក កែល ភារុណ[33]</u>

នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ គ្រូបង្រៀន គឺលោក កែល ភារុណ បានជិះម៉ូតូថ្មីរបស់លោកធ្វើដំណើរក្នុងរាជធានីភ្នំពេញ ពេលនោះ លោកត្រូវបាននគរបាលពីរនាក់បញ្ឈប់ ដោយសារតែម៉ូតូរបស់លោកគ្មានស្លាកលេខ។ មន្ត្រីនគរបាលបានឲ្យលោក កែល ភារុណ ផ្តល់ឯកសារបញ្ជាក់កម្មសិទ្ធិស្របច្បាប់នៃម៉ូតូនោះក្រោយមកលោកបង្ហាញឯកសារបញ្ជាក់ពីកម្មសិទ្ធិនៅប៉ុស្តិ៍នគរបាល។ យ៉ាងណាក៏ដោយ មន្ត្រីនគរបាលបានសម្រេចឃាត់ម៉ូតូរបស់លោកទុករហូតដល់ព្រឹកបន្ទាប់។

បន្ទាប់ពីព្រឹត្តិការណ៍នោះ លោកកែល ភារុណ បានបង្ហោះដំណើររឿងលម្អិតជុំវិញករណីនោះលើទំព័រហ្វេសប៊ុករបស់លោក រួមទាំង បង្ហោះរូបភាពលិខិតនគរបាល ដោយមានខ្លឹមសារថា "ត្រូតពិនិត្យតាមនីតិវិធីនៃនគរបាលខ័ណ្ឌចំការមន"។ បន្ថែមលើនេះ អត្ថបទនៅលើហ្វេសប៊ុក បានសួរមតិយោបល់ពីអ្នកអានថាតើពួកគេគិតថាមានវិធីណាដែលអាចជួយធ្វើឲ្យនីតិវិធីនគរបាលមានភាពប្រសើរឡើងក្នុងករណីបែបនេះ។ ក្នុងរយៈពេលពីរថ្ងៃបន្ទាប់មក ករណីនោះត្រូវបានចេញផ្សាយនៅលើគេហទំព័រ ព័ត៌មាន សប្បាយ ហើយបានផ្សព្វផ្សាយយ៉ាងលឿនពាសពេញអ៊ីនធឺណិត។ ក្នុងខែ កុម្ភៈ លោក កែល ភារុណ ត្រូវបានកោះអញ្ជើញទៅកាន់ប៉ុស្តិ៍នគរបាលដើម្បីសួរនាំពាក់ព័ន្ធនឹងការបរិហារកេរ្តិ៍។ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣ នគរបាលបានសម្រេចមិនធ្វើការចោទប្រកាន់បន្ត បន្ទាប់ពីលោក កែល ភារុណ បានចុះហត្ថលេខាលើលិខិតមួយច្បាប់សន្យាថា លោកនឹងមិនចូលរួមសកម្មភាពដូចគ្នានេះនៅពេលខាងមុខ។

ករណីនេះត្រូវជឿថា ជាករណីដំបូងជុំវិញការសម្តែងមតិយោបល់របស់ប្រជាពលរដ្ឋខ្មែរនៅលើបណ្តាញទំនាក់ទំនងសង្គម រហូតឈានដល់ការគំរាមកំហែងចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ដែលនេះ បង្ហាញឲ្យឃើញពីការប៉ុនប៉ងរបស់រដ្ឋាភិបាលជុំវិញការរិះគន់តាមប្រព័ន្ធផ្សព្វផ្សាយបែបថ្មី។ ករណីនេះបង្ហាញថា ការរិះគន់ បើទោះជាក្នុងកម្រិតតិចតួច ហើយផ្អែកលើព័ត៌មានច្បាស់លាស់ជុំវិញករណីទាំងនោះក្តី នឹងមិនត្រូវបានរដ្ឋាភិបាលអត់ឱនឲ្យនោះទេ។ សំខាន់ជាងនេះទៅទៀត ករណីនោះជាឧទាហរណ៍ដ៏ច្បាស់មួយនៃបញ្ហាជាក់ស្តែងចំពោះការការពារដល់ "កិត្តិយស និងកេរ្តិ៍ឈ្មោះ" របស់ស្ថាប័នទាំងឡាយដូចចែងក្នុងមាត្រា ៣០៥។

<u>លោក សេន សាន</u>

នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣ លោក សេន សាន តំណាងមួយរូបរបស់គណបក្សសង្គ្រោះជាតិ ("គ.ស.ជ") និងលោកស្រី អ៊ុក សំបូរ មកពីភូមិមួយក្នុងខេត្តកណ្តាល ត្រូវលោកឧកញ្ញា ទ្រី ភាព ប្តឹងពីបទបរិហារកេរ្តិ៍។ ពួកគាត់ ត្រូវបានចោទប្រកាន់ ដោយសារតែសម្រង់សម្តីរបស់ពួកគាត់ក្នុងរបាយការណ៍របស់ ក្រុមការងារពិសេសសិទ្ធិមនុស្សកម្ពុជា ("ក.ព.ស.ល.ក") ដែលរបាយការណ៍នោះ បានចោទលោក ភាព ពីបទកាប់

[33] ម.ស.ម.ក "កម្រងករណីសិក្សា៖ កែល ភារុណ ត្រូវបានចោទពីបទបរិហារកេរ្តិ៍តាមរយៈការបង្ហោះមតិយោបល់លើហ្វេសប៊ុក" (សលាកប័ត្រ) (ខែមីនា ឆ្នាំ២០១៣) អាចរកបានតាមរយៈ ៖http://bit.ly/1geX7Rx។

ឈើខុសច្បាប់ និងការចាប់យកដីធ្លីដ៏រាលដាល។[34] របាយការណ៍នោះបានចេញផ្សាយនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០១៣ អះអាងថា ក្រុមហ៊ុនរបស់លោក ភាព បានពង្រីកផ្ទៃដីសម្បទានសេដ្ឋកិច្ចរបស់រដ្ឋាភិបាល រហូតដល់ទំហំប្រហែល ៧០,០០០ ហិកតា ដោយជម្លៀសប្រជាពលរដ្ឋយ៉ាងហោចណាស់ចំនួន ១,៤៤៥ គ្រួសារ ដើម្បីសម្របសម្រួលដល់ក្រុមកាប់ឈើខុសច្បាប់ និងបានរំលោភលើមាត្រា ៤៩ នៃច្បាប់ស្តីពីភូមិបាល ឆ្នាំ ២០០១។[35]

លោក សាន មិនបាននិយាយជាមួយ ក.ព.ស.ល.ក ដោយផ្ទាល់នោះទេ ប៉ុន្តែត្រូវបានរាយការណ៍ដោយបញ្ជាក់ថា លោក ភាព ក្លាយជាអ្នកមានទ្រព្យស្តុកស្តម្ភដោយសារការរកស៊ីកាប់ឈើ ហើយបានចោទលោក ភាព ថា សូកប៉ាន់ដល់ក្រុមគ្រួសាររបស់នាយករដ្ឋមន្ត្រីជាញឹកញាប់។ លោក សាន បានសារភាពថាលោកពិតជាបាននិយាយថាទ្រព្យសម្បត្តិលោក ភាព បានមកពីអាជីវកម្មកាប់ឈើ និងចម្ការកៅស៊ូ ប៉ុន្តែ លោកបានអះអាងថា សម្តីនេះលោកបាននិយាយនៅផ្ទះនោះទេ។ កស្តុតាងជាក់ស្តែងនៃពាក្យសម្តីរបស់លោក គឺតាមខ្សែអាត់សំឡេង ដែលខ្សែអាត់សំឡេងនេះ លោក សាន បានជំទាស់។ ការចោទប្រកាន់លើលោកស្រី អ៊ុក សំបូរ ត្រូវទម្លាក់វិញ បន្ទាប់ពីលោកស្រីបដិសេធថា លោកស្រីពុំបានចោទប្រកាន់លោក ភាព ហើយបានស្តីបន្ទោសលោក សាន ខណៈពេលដែលលោករងការចោទពីបទបរិហារកេរ្តិ៍ តាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ដោយពិន័យជាប្រាក់ចំនួន ពីរសែនរៀល និងបង្គាប់ឲ្យសំណងជំងឺចិត្តចំនួន ពីរលានរៀល ឲ្យទៅលោក ភាព។ មេធាវីការពារក្តីលោក សាន បានប្តឹងជំទាស់នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ ប៉ុន្តែ កាលបរិច្ឆេទសវនាការឧទ្ធរណ៍មិនទាន់ត្រូវបានកំណត់នៅឡើយ។ ប្រសិនបើ លោក សាន ពុំមានលទ្ធភាពបង់ប្រាក់ពិន័យ ដែលមានចំនួនប្រមាណស្មើនឹង ៥៥០ ដុល្លារអាមេរិក ទេនោះ លោកអាចប្រឈមការជាប់ពន្ធនាគារតាមមាត្រា ៥២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

ការចោទប្រកាន់ទាំងនេះ ជាឧទាហរណ៍មួយនៃអ្នកជំនួញជនជាតិកម្ពុជាដ៏មានឥទ្ធិពលជនម្នាក់ បានប្រើប្រាស់តុលាការដើម្បីគំរាមកំហែង ចំពោះជនទាំងឡាយណាដែលហ៊ាននិយាយប្រឆាំងនឹងសកម្មភាពខុសច្បាប់នានារបស់ពួកគេ។ លោក ភាព មានទំនាក់ទំនងយ៉ាងស្និទ្ធជាមួយមន្ត្រីផ្សេងៗ នៅក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម មន្ត្រីរាជអាវុធហត្ថ មន្ត្រីព្រៃឈើ និងសម្បទានិកជនទៃៗទៀតជាច្រើននាក់ ក្នុងនោះ មានលោកស្រី ឈឹង សុភាព ម្ចាស់ក្រុមហ៊ុន ផានអ៊ីមុិច ជាភរិយារបស់ លោក ឡៅ ម៉េងឃីន ជាសមាជិកព្រឹទ្ធសភា គណបក្សប្រជាជនកម្ពុជា (“ប្រ.ជ”) និងជាម្ចាស់ក្រុមហ៊ុន ស៊ូកាគូ ផងដែរ។ ការចោទប្រកាន់ និងវិធានការដ៏ហួសហេតុធ្វើឡើងប្រឆាំងនឹងលោក សាន អាចត្រូវមើលឃើញថា ជារឿងរ៉ាវមានហេតុផលនយោបាយ ប្រធានអង្គការក្រុម

[34] ម៉ៃ ទិត្យថារា “ បណ្តឹងបរិហារកេរ្តិ៍ បន្ទាប់របាយការណ៍របស់អង្គការ” កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៣) អាចរកបានតាមរយៈ http://bit.ly/QW8597 ។

[35] មានប្រភពដូចខាងលើ មាត្រា ៤៩ ចែងថា បុគ្គលម្នាក់ អាចកាន់កាប់ទំហំផ្ទៃដីសម្បទានសេដ្ឋកិច្ចសរុបបានតែ ១០,០០០ ប៉ុណ្ណោះ។

អ្នកច្បាប់ការពារសិទ្ធិកម្ពុជា លោក សុខ សំអឿន បានគូសបញ្ជាក់ថា ទាំងក្រុមហ៊ុន ព្រមទាំងនគរបាលមិនគួរចាត់វិធានការបែបនេះទេ ប្រសិនបើមតិយោបល់នោះត្រូវបានធ្វើឡើងដោយប្រជាពលរដ្ឋសាមញ្ញ។[36]

ការបកស្រាយ និងការអនុវត្តន៍មាត្រា ៣០៥ ដោយនគរបាល ព្រះរាជអាជ្ញា និងតុលាការ បង្ហាញយ៉ាងច្បាស់ថាបទល្មើសព្រហ្មទណ្ឌដុំវិការបរិហារកេរ្តិ៍ ធ្វើឡើងដើម្បីរឹតត្បិតសិទ្ធិសេរីភាពបញ្ចេញមតិដោយផ្ទុយនឹងរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ។ ការបង្ក្រាបនេះ រារាំងដល់ប្រជាពលរដ្ឋខ្មែរក្នុងការអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិរបស់ខ្លួន និងរារាំងពលរដ្ឋក្នុងការចូលរួមក្នុងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រទេសជាតិ។

សេចក្តីសន្និដ្ឋាន

ការបន្តចាត់ទុកការបរិហារកេរ្តិ៍ជាបទល្មើសព្រហ្មទណ្ឌ បង្ហាញនូវបរាជ័យរបស់រដ្ឋាភិបាល ក្នុងការផ្តល់សុពលភាពចំពោះច្បាប់ជាតិ ដែលជាការប្តេជ្ញារបស់រដ្ឋាភិបាល ចំពោះសហគមន៍អន្តរជាតិ និងប្រជាពលរដ្ឋកម្ពុជា។ ខណៈដែល បទប្បញ្ញត្តិនានាស្តីពីការបរិហារកេរ្តិ៍មានចែងក្នុងក្រមព្រហ្មទណ្ឌ អាចត្រូវបានមើលឃើញថាជាការចាំបាច់ សម្រាប់ការពារកេរ្តិ៍ឈ្មោះរបស់ប្រជាពលរដ្ឋ ការចាត់ការបរិហារកេរ្តិ៍ជាបទល្មើសព្រហ្មទណ្ឌបែបនេះពុំសមហេតុផលទៅតាមគោលបំណងនេះទេ។ ទោះបីជា ច្បាប់ស្តីពីរបបសារព័ត៌មាន ផ្តល់ជម្រើសក្នុងការប្តឹងពីបទបរិហារកេរ្តិ៍ ជារឿងក្តីរដ្ឋប្បវេណីក៏ដោយ ក៏ករណីបរិហារកេរ្តិ៍នេះនៅតែចាត់ជាបទល្មើសព្រហ្មទណ្ឌក្នុងក្រមព្រហ្មទណ្ឌ ដែលបង្កើតភាពមិនច្បាស់លាស់តាមផ្លូវច្បាប់ហើយផ្តល់លទ្ធភាពឲ្យរដ្ឋាភិបាលអនុវត្តច្បាប់នេះដើម្បីបំពេញបំណងនយោបាយរបស់ខ្លួន។ ដោយសារតែមានទំនាក់ទំនងរឹងមាំរវាងតុលាការ និងរដ្ឋាភិបាល ការបរិហារកេរ្តិ៍ និងបទចោទដទៃៗទៀត ជានិច្ចជាកាល ត្រូវបានអនុវត្តពុំត្រឹមត្រូវ ដើម្បីគាបសង្កត់ខុសច្បាប់លើសេរីភាពបញ្ចេញមតិ និងរឹតត្បិតលើការរិះគន់ដុំវិញបញ្ហាសំខាន់នានាចំពោះប្រជាពលរដ្ឋកម្ពុជា។ មន្ត្រីជាន់ខ្ពស់ មានចេតនាអនុវត្តបទល្មើសព្រហ្មទណ្ឌនៅពេលប្រឈមនឹងការរិះគន់ ជាជាង លើកឡើងពីការចោទប្រកាន់ជាសាធារណៈ ហើយច្បាប់បច្ចុប្បន្ននេះអាចជួយពួកគេឲ្យសម្រេចបំណងបាន។

ការចាត់ទុកការបរិហារកេរ្តិ៍ជាបទល្មើសព្រហ្មទណ្ឌ តាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ និងវិធីអនុវត្តមាត្រានេះ គឺអធម្មនុញ្ញភាព។ ចំណុចនេះ រំលោភលើការធានាក្នុង មាត្រា ៤១ និងមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញ។ ការរឹតត្បិតណាមួយលើសេរីភាពទាំងនេះត្រូវចៀសវាង លើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះ ហើយរដ្ឋាភិបាលមិនទាន់បានបង្ហាញពីភាពចាំបាច់ដុំវិញការដាក់ពិន័យលើការបរិហារកេរ្តិ៍ និងការការពារដល់កេរ្តិ៍ឈ្មោះតាមរយៈការចោទប្រកាន់ពីបទព្រហ្មទណ្ឌនោះទេ។ ម្យ៉ាងវិញទៀត បទប្បញ្ញត្តិមានចែងនៅក្នុងមាត្រា ៣០៥ និងមាត្រាដទៃទៀតនៃក្រមព្រហ្មទណ្ឌ មានខ្លឹមសារមិនច្បាស់លាស់ ហើយនិយមន័យមានលក្ខណៈបើកចំហធ្វើឲ្យមានការបកស្រាយទូលំទូលាយពេក ដូច្នោះធ្វើឲ្យមានការប្រើប្រាស់ច្បាប់ដោយខុស។

ក្នុងអំឡុងពេល ការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់ ទាំងក្នុងឆ្នាំ២០០៩ [37] និងឆ្នាំ ២០១៤[38] រដ្ឋសមាជិកដទៃទៀតបានផ្តល់អនុសាសន៍ដល់រដ្ឋាភិបាល ឲ្យពិនិត្យឡើងវិញចំពោះនិយមន័យនៃបទ

[36] មានប្រភពដូចខាងលើ។

បរិហារកេរ្តិ៍ និងដើម្បីបញ្ចៀសការតបតពុំសមហេតុផល។ រដ្ឋាភិបាលបានទទួលយកអនុសាសន៍ទាំងនោះ ក្នុងពេលត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់នោះ ប៉ុន្តែ រដ្ឋាភិបាលខកខានក្នុងការអនុវត្តតាមអនុសាសន៍ទាំងនោះជារហូតមក។ ជាលទ្ធផល ច្បាប់កម្ពុជានៅតែខកខានក្នុងការគោរពឲ្យបានគ្រប់ជ្រុងជ្រោយលើសិទ្ធិសេរីភាពបញ្ចេញមតិ និងបរាជ័យក្នុងការប្រតិបត្តិតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។ នេះបង្ហាញយ៉ាងច្បាស់ពីការចាំបាច់ក្នុងការធ្វើវិសោធនកម្មច្បាប់បរិហារកេរ្តិ៍នាពេលបច្ចុប្បន្ននេះ។

ដោយសារហេតុនោះ ម.ស.ម.ក ផ្តល់អនុសាសន៍ជូនរដ្ឋាភិបាល ដូចខាងក្រោម៖

- ដកការបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌ ក្នុងមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ
- ដកការប្រមាថមន្ត្រីសាធារណៈចេញពីបទព្រហ្មទណ្ឌ ក្នុងមាត្រា ៥០២ នៃក្រមព្រហ្មទណ្ឌ និងដកការធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ចេញពីបទព្រហ្មទណ្ឌចំពោះ ក្នុងមាត្រា ៥២៣ ព្រោះថា មាត្រាទាំងពីរនេះ មិនស្របតាម កន.ព.ស.អ. និងពុំស្របជាមួយរដ្ឋធម្មនុញ្ញ។
- ជាវិធានការបណ្តោះអាសន្ន រដ្ឋាភិបាលគួរកំណត់ការអនុវត្តន៍នៃច្បាប់បរិហារកេរ្តិ៍នោះ ចំពោះតែករណីធ្ងន់ធ្ងរប្រឆាំងលើបុគ្គលប៉ុណ្ណោះ និងគួរធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌដើម្បីបកស្រាយឲ្យបានច្បាស់នូវពាក្យបច្ចេកទេសដែលមានលក្ខណៈស្រពេចស្រពិល ហើយ
- ចាត់វិធានការចាំបាច់នានាទាំងអស់ ដើម្បីកុំឲ្យស្ថាប័នរដ្ឋខ្ជះខ្ជាយធនធានរបស់ជាតិ និងបំពេញតួនាទីតាមពេលវេលាដ៏មានតម្លៃរបស់តុលាការ តាមការចោទនានាពីបទបរិហារកេរ្តិ៍។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង កញ្ញា សន រ៉ាមណា អ្នកសម្របសម្រួលគម្រោងសេរីភាពបញ្ចេញមតិរបស់ ម.ស.ម.ក តាមរយៈទូរសព្ទលេខ៖ +៨៥៥(០)១៧ ៦៥៥ ៥៩១ ឬតាមរយៈ អ៊ីម៉ែល៖ ramanasorn@cchrcambodia.org ឬកញ្ញា ហ្សូលីយ៉ែត រ៉ូស្សេឡត ទីប្រឹក្សារបស់ ម.ស.ម.ក តាមរយៈ ទូរសព្ទ៖ +៨៥៥(០) ១៥៣៥ ០៦២០ ឬអ៊ីម៉ែល៖ julietterousselot@cchrcambodia.org។

[37] អនុសាសន៍ ក-៤៦ (ង) ដោយចក្រកពអង់គ្លេស អាចរកបានតាមរយៈ:http://bit.ly/1bKGOiT ។

[38] អនុសាសន៍លេខ ១១៨.១០៣ ដោយប្រទេសអាឡឺម៉ង់ និង អនុសាសន៍លេខ ១១៩.២៧ ដោយសហរដ្ឋអាមេរិក អាចរកបានតាម៖ http://bit.ly/1fj4ryh។